# ប្រវត្តិសង្ខេប នៃ វត្តធម្មារាម

ដោយឧត្តមគតិដ៏ឧដុង្គឧត្តមនៃគណៈកម្មការចាស់ទុំដែលបានភៀសខ្លួនដោយសង្គ្រាមមកដល់ទីនេះមុន ដោយហេតុតែ ខ្មែរធ្លាប់ស្រឡាញ់និងគោរពព្រះពុទ្ធសាសនា ប្រពៃណីទំនៀមទម្លាប់, ក៏បាននាំគ្នានិមន្តភិក្ខុ ១ អង្គព្រះនាម **ធម្មវរៈ ប៉ែល ឡុង** មានព្រះជន្ម ៩២ ឆ្នាំ មកគង់នៅជាបណ្តោះអាសន្ននៅផ្ទះលោក**អ៊ុន ពឹម** និងផ្ទះលោក**ម៉ុក សំ** ។ បន្ទាប់មកក៏បានមូលមតិគ្នាបង្កើតជាគណៈកម្មការ ដើម្បីដើររកជាវដីធ្វើវត្ត ក៏បានឃើញដីមួយកន្លែង មានអាសយដ្ឋានលេខ 3732 E. Carpenter Road Stockton, CA 95215 មានទំហំដីចំនួន ៥ អេក័រ នៅលើដីនោះមានផ្ទះពីរខ្នងតម្លៃ $៨0,000 ដែលជាកន្លែងវត្តសព្វថ្ងៃនេះ ។ ដល់ថ្ងៃទី១៨ ខែសីហាឆ្នាំ ១៩៨២ បាននិមន្តព្រះតេជព្រះគុណ **ធម្មវរៈមហាថេរៈ** ព្រះនាម **ប៉ែល ឡុង** ជាព្រះថេរៈចាស់ទុំក្នុងព្រះពុទ្ធសាសនាផ្នែក **ថេរវាទ** មកគង់ជា **ព្រះចៅអធិការ** និង **ព្រះឧបជ្ឈាយ៍** ជារៀងរហូត ។

## សមាសភាពនៃគណៈកម្មការមុនដំបូងបង្អស់គឺ :

ព្រះតេជព្រះគុណ**ធម្មវរៈ ប៉ែល ឡុង** ជាចៅអធិការ

លោក **ម៉ា ឡាពី** ជាប្រធានគណៈកម្មការ លោក **ម៉ី វ៉ារឿន** ជាអាចារ្យវត្ត លោក **ស សឿន**, លោក **ម៉ុក សំ**, លោក **គិត ប៉ុង**, លោក **ទុង សេង**, លោក **អ៊ុន ពឹម**, លោក **ស្រី វ៉ែន**, លោក **រស់ ណារិទ្ធ** លោក **សំ ចាន់ណាក់**, លោក **ចឿន រាម**, លោក **មាស ស៊ិន**, លោក **មួង ចន្ទដារ**, លោក **គឹម អុល**, លោក **តាន់ ស៊ុន**, លោក **គា ជាវលី** ។

ដោយស្រឡាញ់ដីនេះនឹងចង់បានឱ្យទីនេះកើតបានជាវត្តពិតប្រាកដនោះ នៅឆ្នាំ ១៩៨៣ បានរួបរួមគ្នាបង្កើតគណៈកម្មការ ថ្មីដើម្បីរកប្រាក់សងថ្លៃដីនិងកុដិ ។

## ឯគណៈកម្មការថ្មីនោះមាននាមដូចតនៅនេះ ៖

ព្រះតេជព្រះគុណ**ធម្មវរៈ ប៉ែល ឡុង** ជាព្រះចៅអធិការ

លោក **នេត សំអួន** ប្រធានគណៈកម្មការ, លោក **អ៊ី ចាន់ថន** អនុប្រធានគណៈកម្មការ, លោក **រស់ រឿន** អាចារ្យវត្ត លោក **អ៊ុន ពឹម** ហេរញ្ញិក លោក **រស់ ណារិទ្ធ** ហេរញ្ញិករង លោក **គឹម សំអុល** អគ្គពិនិត្យ លោក **សៅ ហ៊ាន** លេខាធិការ, លោក **ហ៊ិច ពឿន** បំរើការទូទៅ, លោកឯកឧត្តម **សូ ខាំខូយ** ទីប្រឹក្សាកិត្តិយស

លោក **ពេជ្រ សុធីរ** សមាជិកសកម្ម, លោក **ញូង មិន** ទីប្រឹក្សា, លោក **ញៀវ សឿន** ទីប្រឹក្សា, លោក **សុខ រស់** ទីប្រឹក្សា

**មានសមាជិកសកម្មជាច្រើនទៀតដែលយើងចាំមិនអស់សូមអភ័យទោស**

**ផ្នែកដូនជីមានដូចតទៅនេះ ៖**

លោកយាយ **ផាំច** ប្រធានដូនជី លោកយាយ**ឃុន សៀង** អនុប្រធានដូនជី លោកយាយ **អៀម រ៉ុន** សមាជិកា

លោកយាយ **សុខ យ៉ាត** សមាជិកា លោកយាយ **ជិន** សមាជិកា លោកយាយ **ចាប ឃិន** សមាជិកា

លោកយាយ **មិន គង់** សមាជិកា លោកយាយ **សៀក ទ៉េន** សមាជិកា

គណៈកម្មការខាងលើនេះបានប្រសិទ្ធិនាមនៃវត្តនេះថា **"វត្តធម្មារាម"** ដើម្បីឱ្យស្របទៅតាមនាមឆាយារបស់ព្រះតេជ ព្រះគុណ **ប៉ែល ឡុង**។ នៅឆ្នាំ ១៩៨៤ បានសងថ្លៃដីនិងកុដិរួចជាស្ថាពរ ហើយគណៈកម្មការនោះគ្មានសកម្មភាពកសាង នូវអ្វីថ្មីទៀតទេ។

ជាថ្មី នៅថ្ងៃអាទិត្យទី៦ ខែឧសភា ឆ្នាំ១៩៩៣ បានរៀបចំជ្រើសរើសចាត់តាំងគណៈកម្មការថ្មី ដើម្បីកសាងសេនាសនៈផ្សេងៗ នឹងរៀបចំនៅទីអារាមទាំងមូលឱ្យបានសមរម្យជាទីគោរពសក្ការៈនៃពុទ្ធបរិស័ទទូទៅក្រោមព្រះអធិបតីភាព នៃ **សម្តេច ធម្មវរៈមហាថេរៈ** ព្រះនាម **ប៉ែល ឡុង** ដោយបានជ្រើសរើសដាក់ឈ្មោះជាថ្មីថា **"ពុទ្ធិកសមាគមខ្មែរ នៃ វត្តធម្មារាម"** ទីក្រុង**ស្តុកតុន** រដ្ឋ**កាលីហ្វរនីញ៉ា**។

**វត្តធម្មារាម** ជាវត្តរបស់ខ្មែរភៀសខ្លួនដោយសង្គ្រាមបានរួមសាមគ្គីគ្នា ជាមួយនឹងព្រះសង្ឃកសាងនូវវត្តនេះដើម្បីថែរក្សានូវទំនៀមទម្លាប់ប្រពៃណីជាតិប្រពៃណីសាសនានិងសម្បត្តិវប្បធម៌ដ៏ថ្លៃថ្លារបស់ដូនតាយើងឱ្យបានគង់វង។ ប្រជាជនភៀសខ្លួនខ្មែរធ្លាប់មានស្នាដៃឯកក្នុងការកសាងហើយ**កម្ពុជបុត្ត**បានរងនូវសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក

ឥឡូវនេះ **កុលបុត្តកុលធីតាខ្មែរ** ទាំងអស់គ្នាបានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ក្រៃលែងនោះ ដែលពិភពលោកមិនធ្លាប់បានជួបប្រទះ, ចាកផុតពីអំពើឃោរឃៅ បញ្ចប់នូវគំនុំគុំគួន រៀបចំខ្លួនឱ្យបានសមស្របដើម្បីរស់នៅលើទឹកដីថ្មី ដើរតាមពុទ្ធឱវាទនៃព្រះជិនស្រី ខិតខំព្យាយាមពុះពារគ្រប់ឧបស័គ្គតូចធំ ចាប់ដៃគ្នាកសាងនូវអារាមដ៏ស្រស់ត្រកាលនេះ ដើម្បីឧទ្ទិសថ្វាយចំពោះគុណព្រះរតនៈត្រ័យ។

សមាសភាពនៃគណៈកម្មការ **ពុទ្ធិកសមាគមខ្មែរ នៃ វត្តធម្មារាម** ដែលរៀបចំថ្មីមានដូចតទៅនេះ ៖

សម្តេច **ធម្មវរៈមហាថេរៈ ប៉ែល ឡុង** ជាព្រះចៅអធិការ

ភិក្ខុ **ធម្មរតនោ ឡាច ធួក** ជាព្រះចៅអធិការរងទី ១ ភិក្ខុ **ធម្មលិខិត្តោ គួច ពុំ** ជាព្រះចៅអធិការរងទី ២

## ផ្នែកគ្រហស្ថ ៖

លោក **ប៊ិន ប្អូន** ប្រធានពុទ្ធិកសមាគមខ្មែរ នៃ វត្តធម្មារាម

លោក **សោម អាន** អនុប្រធានទី ១ លោក **ឡុង យ៉ុន** អនុប្រធានទី ២

លោក **សូ កប** អគ្គលេខាធិការ លោក **ម៉ី ខ៊ាន់** អនុលេខាធិការ

លោក **ស៊ឹង ឡេង** ហេរញ្ញិកទី ១ លោក **ហ៊ិប ពឿន** ហេរញ្ញិកទី ២

លោក **ខ៊ាន់ អ៊ុង** អាចារ្យវត្តទី ១ លោក **ផូ សាល្មួន** អាចារ្យវត្តទី ២ លោក **ប្រែង ម៉ូ** អាចារ្យវត្តទី ៣

## ទីប្រឹក្សាវត្ត ៖

លោក **នេត សំអួន**, លោក **អ៊ី ចាន់ថន**, លោក **ឯក លឿន**, លោក **ទេព កោសល្យ**, លោក **រស់ នឹម**

## ផ្នែកមន្ទីរឃោសនាការ ៖

លោក **ឈុន ហ៊ុន**, លោក **ខន្ធ ចាន់ថា**, លោក **ប៉ែន អុល**, លោក **ហេង ឈន**, លោក **អឿន អឿម**, លោក **ស៊ិន សុខ**

## ផ្នែករដ្ឋបាល ៖

លោក **សែម សច្ចា**

## ផ្នែកអនាម័យ ៖

វត្តធម្មារាម

លោក **សូ ខ៊ាន់**, លោក **ម៉ាត់ សេង**, លោក **ឱក សុខុន**, លោក **សេង ម៉ាត់លី** ។

គណៈកម្មការ **ពុទ្ធិកសមាគមខ្មែរ នៃ វត្តធម្មារាម** បានរៀបចំនិងចាត់តាំងទៅតាមផ្នែកនីមួយៗរួចហើយ ក៏ផ្ដើមសង់កុដិថ្មីមួយមានបន្ទប់សំរាប់ព្រះសង្ឃគង់ ៩ មានបន្ទប់ទឹក ៥ អស់តម្លៃ ៣៣៥,000 ដុល្លារ ។

ដោយកម្លាំងសាមគ្គីដ៏ខ្លាំងក្លារបស់ពុទ្ធបរិស័ទនៅក្រុងស្តុកតុននិងនៅក្រៅក្រុងស្តុកតុន បានសងប្រាក់ធនាគារហើយរួចរាល់នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ១៩៩៥ ។

ថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៩៥ គណៈកម្មការថ្មី (លើកទី៤) ដោយមានការផ្លាស់ប្តូរមុខនាទីខ្លះតែមនុស្សរនៅដដែល បានសំរេចជាឯកច្ឆ័ន្ទ សង់ឧបដ្ឋានសាលាសំរាប់ធ្វើបុណ្យទានផ្សេងៗ ។ រីឯសមាសភាពនៃគណៈកម្មការ**ពុទ្ធិកសមាគមខ្មែរ នៃ វត្តធម្មារាម** ក្នុងអាណត្តិទី ៤ នេះមានដូចតទៅ ៖

សម្តេច **ធម្មវរៈមហាថេរៈ ប៉ែល ឡុង** ជាចៅអធិការ

ភិក្ខុ **ធម្មតេជោ ឡាច ឆួក** ប្រធានពុទ្ធិកសមាគមខ្មែរ

ភិក្ខុ **ធម្មលិខិត្តោ គុច ពុំ** អនុប្រធានទី ១ ភិក្ខុ **ពុទ្ធសរណោ កែន អែល** អនុប្រធានទី ២

លោក **សែម សច្ចា** កិច្ចការផ្នែករដ្ឋបាល លោក **ប៊ិន ប្អូន** បដិសណ្ឋារៈ

លោក **ម៉ី ច៉ាន់** លេខាធិការ, លោក **ញ៉ៀម សុផន** លេខាធិការរងទី១, លោក **កែន ចេង** លេខាធិការរងទី២

លោក **សឹង ឆៀង** ហេរញ្ញិក លោក **សោម អាង** ហេរញ្ញិករងទី១, លោក **ហ៊ិប ពឿន** ហេរញ្ញិករងទី២

លោក **ច៉ាន់ អ៊ុង** អាចារ្យវត្តទី ១, លោក **ផូ សាលួន** អាចារ្យវត្តទី ២, លោក **ច្រែង ប៊ូ** អាចារ្យវត្តទី ៣

**ផ្នែកទីប្រឹក្សាវត្តគី :**

លោក **អ៊ី ចាន់ថន**, លោក **នេត សំអួន**, លោក **រស់ នឹម**, លោក **ឈុន ហ៊ុន**, លោក **ផៅ សរ**

**អ្នកជំនួយកិច្ចការវត្ត :**

លោក **ខិក សុខុន** លោក **អឿន អឿម**

**គណៈកម្មការពិនិត្យ :**

ភិក្ខុ **កែន អែល** ប្រធានអគ្គពិនិត្យ

លោក **រស់ នឹម**, អគ្គពិនិត្យរងទី១ លោក **នេត សំអួន**, អគ្គពិនិត្យរងទី២ អ្នកស្រី **ម៉ៅ ត័ព្វ** អគ្គពិនិត្យទី៣

**គណៈកម្មការឃោសនាការ :**

លោក **នេត សំអួន** លោក **អ៊ី ចាន់ថន** លោក **រស់ នឹម** លោក **ច្រែង ប៊ូ** លោក **ផៅ សរ** លោក **ម៉ែន អុល**

**អ្នកបើករថយន្តបំរើព្រះសង្ឃ :** លោក **សុខ ច្រាង**

**ខាងលំអដាំដុះនិងថែរក្សាសួនច្បារ :** លោក **កុយ សុខ**, លោក **សឹង អឿង**, លោក **ច៉ាន់ ឈុំ**,

**អ្នកកាន់ខ្មក្បោសនស័ព្ទ :** លោក **អេង ឡេង**, លោក **ប៊ុន សារិន**

**អ្នកទទួលខុសត្រូវគរុភ័ណ្ឌចេញនិងចូល :** លោកតា **ម៉ែន សន**, យុវជន **ខែមរ៉ា**

**ផ្នែករៀបចំភោជនាហារ :** អ្នកស្រី **ទេព យឿន** អ្នកស្រី **សេង កែ** អ្នកស្រី **ទេស សុន** អ្នកស្រី **ឡាច សំ**

**ជំនួយកិច្ចការទូទៅនិងសម្ភារៈគ្រប់យ៉ាង :** អ្នកស្រី **លី គឹមលាង**, អ្នកស្រី **ផល់ ហេង**, អ្នកស្រី **ជា ទិត**, អ្នកស្រី **ប្អូ ថុន**, អ្នកស្រី **ឡាក់ ឈឹម**, អ្នកស្រី **ម៉ៅ ត័ព្វ**, អ្នកស្រី **កែវ បឿន**, អ្នកស្រី **ទី អាន់**, អ្នកស្រី **អ៊ុក ណារិទ្ធ**,ក្នុងការសាងសង់នូវឧបដ្ឋានសាលានេះអស់តម្លៃ ៦១០០០០ដុល្លារមានចំណតសំរាប់ចតឡានចំនួន១២០ នៅពេលសាងសង់ នោះដោយមានលោក**សោម ខុន** អ្នកស្រី**នុត ចាន់ណារី** លោក**តា ជាវលី** អ្នកស្រី**ខ្ញូច យ៉ាទី**

លោកវេជ្ជបណ្ឌិត**សេង ហ៊ត** អ្នកគ្រូពេទ្យ**សេង សារួត** លោក**គុយ សាវ៉ាន់** និងអ្នកស្រី ។ លោកទាំង៤គ្រួសារនេះជាញោមវត្តបានឈរឈ្មោះជួយធានារ៉ាប់រងខ្ចីប្រាក់ពីធនាគារដើម្បីឱ្យគណៈកម្មការសង់នូវឧបដ្ឋានសាលារហូតបានសម្រេចជាស្ថាពរនៅក្នុងពេលកំពុងស្ថាបនាឧបដ្ឋានសាលា គណៈកម្មការលើកទី៤បានចាត់តាំងឱ្យលោក **ស៊ឹង ឡៀង** និងលោក **ហ៊ិប ពឿន** ធ្វើជាប្រធាននិងអនុប្រធានសាងសង់ចុះផ្ទាល់ជាមួយជាងសំណង់នៃ អាមេរិកាំង រហូតដល់ការនោះបានហើយសព្វគ្រប់ ។

នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៩៦ ព្រះសង្ឃនិងគណៈកម្មការវត្តព្រមទាំងគណៈកម្មការតាមភូមិនានា បានប្រារព្ធធ្វើពិធីបុណ្យសម្ពោធកាត់ខ្សែបូ ដើម្បីបើកនូវទ្វារនៃឧបដ្ឋានសាលាឱ្យប្រើប្រាស់ជាផ្លូវការតទៅ ។ នៅពេលធ្វើពិធីកាត់ខ្សែបូនោះរដ្ឋបានប្រគល់ ច្បាប់អនុញ្ញាតឱ្យបានធ្វើជាវត្តពិតប្រាកដស្របទៅតាមច្បាប់នៃទីក្រុង **ស្តុកតុន សហរដ្ឋអាមេរិក** ។

ការរីកចំរើននៃ **វត្តធម្មារាម** ក្រោយពីកសាងកុដិនិងឧបដ្ឋានសាលារួចមក ភ្លាមនោះ **ពុទ្ធិកសមាគមខ្មែរ នៃវត្តធម្មារាម** យើងបានធានាព្រះសង្ឃពីរអង្គមកពី **ភ្នំពេញ នៃ ព្រះរាជាណាចក្រកម្ពុជា** ដើម្បីបានមកគង់ចាំវស្សានៅក្នុងវត្តធម្មារាម ។ ភិក្ខុទី១ព្រះនាម **គុយ ឆាន** ជាគ្រូខាងសមាធិ ភិក្ខុទី២ព្រះនាម **ញ៉ា សំណាង** ជាគ្រូខាង បរិយត្តិ ។

នៅក្នុងរដូវវស្សាឆ្នាំជូតអដ្ឋស័ក**ព.ស.២៥៤០ គ.ស.១៩៩៦** ភិក្ខុ **គុយ ឆាន** ក៏បានយកព្រះទ័យទុកដាក់បង្ហាត់បង្រៀនតាយាយ មានលោកគ្រូ**ផូ សាលួន**ជាគ្រូជំនួយផង ។ តា យាយដែលមានសទ្ធាបានប្រគល់កាយថ្វាយខ្លួនចំពោះគុណព្រះរតនៈត្រ័យនាំគ្នារក្សានូវបាដិហារិយបក្ខុបោសថ និងធ្វើសមាធិចំនួន៣ខែនៅក្នុងវត្តធម្មារាម ក្រុងស្តុកតុន ។

ឯតា យាយដែលបាននាំគ្នាធ្វើសមាធិនោះមានគ្នា១៦នាក់ ដូចមានរាយនាមតទៅនេះ ៖

១. តា **ឡុង យ៉ុន** ២. យាយ **ឆឿង យ៉ាត** ៣. យាយ **វរៈរតនៈ មុនីទេវី** ៤. យាយ **មាស ទូច**
៥. យាយ **អ៊ិន នាង** ៦. យាយ **ទិត យ៉ាន់** ៧. យាយ **អៀម រ៉ុន** ៨. យាយ **ឡឹង ផល្លា**
៩. យាយ **គង់ ម៉ុន** ១០. យាយ **យ៉េង ហាប់** ១១. យាយ **ម៉ាក់ យន** ១២. យាយ **ចាប ឃិន**
១៣. យាយ **អ៊ុក ហ៊ន** ១៤. យាយ **ស្តើង យ៉ុម** ១៥. យាយ **ខ ស៊ាន** ១៦. យាយ **អ៊ូ សារី**

ចំណែក ភិក្ខុ **ញ៉ា សំណាង** ក៏បានបង្រៀនធម៌វិន័យដែលជាឫសគល់នៃព្រះពុទ្ធសាសនាដល់ភិក្ខុដែលគង់ចាំវស្សានៅវត្តធម្មារាមផងដែរ ។

ឯកិច្ចធ្វើសមាធិក៏បានធ្វើបន្តមកដល់សព្វថ្ងៃនេះ បង្រៀនដោយ លោកគ្រូធម្មាចារ្យ **ផូ សាលួន** ដូច្នេះសូមអញ្ជើញពុទ្ធបរិស័ទ ដែលមានបំណងក្នុងកិច្ចធ្វើសមាធិនេះ **វត្តធម្មារាម** សូមស្វាគមន៍ជានិច្ច ។

នៅឆ្នាំ ១៩៩៧ បានជាវដីមួយកន្លែងទៀត នៅពីខាងកើតដីចាស់ មានទំហំនិងប្រវែងដីចាស់ នៅលើដីនោះមានផ្ទះពីរខ្នងតម្លៃដីនោះ $១៧០,០០០ ។

នៅក្នុងខែ ៥ ថ្ងៃទី១១ ឆ្នាំ១៩៩៧ **ព្រះតេជព្រះគុណព្រះអគ្គគ្រូព្រះនាម គង់ ទិត្យ គន្ធបញ្ញោ** បាននិមន្តមកដល់ **វត្តធម្មារាម** ដោយឧបាសិកា **សៀក ម៉េន** បានសុំឱ្យ **ពុទ្ធិកសមាគមខ្មែរ នៃ វត្តធម្មារាម** ជួយធានាព្រះអង្គ ។ ចាប់តាំងពីបាននិមន្តមកគង់នៅក្នុងវត្តធម្មារាមកាលណា ព្រះអង្គបានយកព្រះទ័យទុកដាក់ក្នុងការរៀបចំរចនាកសាងនូវរូប ចម្លាក់ផ្សេងៗមានព្រះពុទ្ធរូបជាដើម ។

នៅឆ្នាំ ១៩៩៩ លោក **ហុង គុកហួរ** និងអ្នកស្រី **តី សាម៉ុន** បានផ្តើមកសាងរបងពីខាងមុខពីស៊ីម៉ងត៍, ហើយមានសមាជិកសមាជិកាបានចូលរួមជួយឧបត្ថម្ភលោកផងគឺលោក **ម៉ុក សំ** អ្នកស្រី **នូ ឡើ** លោក **គា ជាវលី** អ្នកស្រី **ទួច យ៉ាវី** លោក **សោម ខុន** អ្នកស្រី **នុត ចាន់ណារី** លោក **ឫ លីហេង** អ្នកស្រី **ប៉ុល សុផល** លោក **តាន់ ស៊ុន** អ្នកស្រី **សៀក នេត្រ** លោកវេជ្ជបណ្ឌិត **សេង ហីត** អ្នកគ្រូពេទ្យ **សេង សារួត** ។ ក្នុងការកសាងនេះអស់ប្រាក់ចំនួន $៧០,០០០ ។

នៅថ្ងៃអង្គារ ៨ រោចខែបឋមាសាធឆ្នាំមមីចត្វាស័ក**ព.ស.២៥៤៦**ត្រូវនឹងថ្ងៃទី ២ ខែកក្កដា**គ.ស.២០០២** ផ្តើមកសាង ខ្លោងទ្វារ ដឹកនាំកសាងដោយព្រះអង្គចៅអធិការ**ធម្មលិខិត្តោព្រះនាម គុច ពុំ** ។ ក្បូរក្បាច់រចនាដោយលោក **អ៊ុច ពៅ** ប្រធានសំណង់គឺលោក **ហ៊ុប ពឿន**, មានលោក **សោម តាន**, លោក **សៅ សាខុន**, លោក **ម៉េន មាន**, លោក**ម៉ាត់ សេង**, លោក**ស្រី ហឿន** បានចុះធ្វើជាប់ជាមួយមេជាងនិងប្រធានសាងសង់ ។ ក្នុងការកសាងស្ថាបនានូវខ្លោងទ្វារនេះអស់ប្រាក់$ ៨០,០០០រួមនឹងផ្លូវផង ។

នៅឆ្នាំ ២០០២ ដដែល ព្រះអង្គចៅអធិការនិងព្រះសង្គគ្រូព្រះនាម **គង់ ទិត្យ** បានផ្តើមកសាងលើកទី១នូវរូបចម្លាក់ព្រះ **មោគ្គល្លានផ្ចាញ់នន្ទោបនន្ទនាគ** ក្នុងការកសាងនូវក្បូរក្បាច់រចនាផ្សេងៗ គឺព្រះអង្គធ្វើផ្ទាល់ព្រះ-ហស្តព្រះអង្គឯង ឥតមានបានជួលជាងទេ ក្នុងការធ្វើនេះអស់ប្រាក់ចំនួន $ ១៣,០០០ មានភិក្ខុ សាមណេរ ឧបាសក ឧបាសិកា តាជី ដូនជី បានជួយធ្វើជាមួយផង ។

បន្ទាប់ពីបានធ្វើរូបចម្លាក់ព្រះ **មោគ្គល្លានផ្ចាញ់** នូវ **នន្ទោបនន្ទនាគ** រួចមក ក៏ចាប់ផ្តើមកសាងនូវ **សំវេជនីយដ្ឋានទាំង៤** នៅជុំវិញដើមពោធិ៍គឺ **ប្រសូត ត្រាស់ដឹង សំដែងធម្មចក្កប្បវត្តនសូត្រ** និង **បរិនិព្វា.** ក្នុងការកសាងនូវ **សំវេជនីយដ្ឋានទាំង៤** និងរូបចម្លាក់ផ្សេងៗ មានពុទ្ធបរិស័ទចុះជួយធ្វើជាមួយនឹងព្រះអង្គគ្រូទាំង

យប់ទាំង ថ្ងៃដោយសទ្ធាជ្រះថ្លាយកបុណ្យកុសលឥតបានគិតពីប្រាក់កាសអ្វីឡើយ ឯអស់លោកទាំងនោះដូចមានរាយនាមតទៅនេះ ៖

## គណៈកម្មការបំរើវត្ត និងកសាងព្រះ

១. លោក **គុណ សារ៉ា** អ្នកស្រី **ភង សុខុម**
២. លោក **ច្រែង ជ្រឹម** អ្នកស្រី **ពេជ្រ សាម្ងន**
៣. លោក **ប៉ុក ហាង** អ្នកស្រី **ជិន ស៊ីនួន**
៤. លោក **លី អឿន** អ្នកស្រី **ញឹន សារឿន**
៥. លោក **នូ ម៉ឿន** អ្នកស្រី **ទឹម សារឿន**
៦. លោក **អ៊ុន សុផានី** អ្នកស្រី **ឆាយ ពៅ**
៧. លោក **អ៊ុង ណេង** អ្នកស្រី **អួន យួន**
៨. លោក **អ៊ុន គិន** អ្នកស្រី **ភង សេម**
៩. លោក **យិន ឡៀង** អ្នកស្រី **អ៊ី ណែម**
១០. លោក **ពោង ជន** អ្នកស្រី **ប៊ុត គឹម**
១១. អ្នកស្រី **ស៊ុន សីលា**
១២. អ្នកស្រី **ណុប រិទ្ធ** យុវជន **លី សម្ពី**
១៣. អ្នកស្រី **ហ៊ុត តែ**
១៤. អ្នកស្រី **ប៊ុន សុតី**
១៥. លោកអាចារ្យ **ប៉ៅ សរ** អ្នកស្រី **សែម សាវន**
១៦. លោក **ចាន់ កុសល** អ្នកស្រី **ចាន់ នី**
១៧. លោក **ឡុច ចក្ខុរតនោ** អ្នកស្រី **ឡុច សុភាព**
១៨. លោក **អ៊ិន លី** អ្នកស្រី **ប៉ុក សារ៉េង**
១៩. លោក **មិន ហ៊ីង** អ្នកស្រី **ពៅ សាវឿន**
២០. លោក **ដា វ៉ាន់** អ្នកស្រី **ឌិន ដាលីន**
២១. យុវជន **ជា ដេត**
២២. លោក **សូ វណ្ណា** អ្នកស្រី **ឌ៉ាន់ ចាន់**
២៣. លោក **ឥន្ទ អៀម** អ្នកស្រី **ហែម ច័ន្ទធី**
២៤. លោក **មាស ម៉ៅ** អ្នកស្រី **ប៊ិន អែត**
២៥. លោក **សួស សម្បត្តិ** អ្នកស្រី **យូ សារ៉ុន**
២៦. លោក **សួ សួង** អ្នកស្រី **ខែត្រ ស៊ីចាន់**
២៧. លោក **សាឡាយ សាប៊ូ** អ្នកស្រី **អៀង សឿត**
២៨. លោក **ហ៊ី ហួត** អ្នកស្រី **យុន សុខល់**
២៩. លោក **ម៉ាត់ សេង** អ្នកស្រី **ប្ញ ថុន**
៣០. លោក **ហែម គឹមហេង** អ្នកស្រី **ឌិត្យ សុផល់**
៣១. លោក **កែន ចេង** អ្នកស្រី **យ៉ាន់ សំបឿន**
៣២. លោក **ឌ៉ាត់ ភាព** អ្នកស្រី **សុទ្ធ សុខុន**
៣៣. អ្នកស្រី **តេង ហ៊ាន**
៣៤. លោក **សុិញ ស៊ីរីតរិទ្ធី** អ្នកស្រី **នី ស៊ាបកិស្សរាយោ**
៣៥. លោក **ហឿន ម៉ន** អ្នកស្រី **ខែម ម៉ឿយ**
៣៥. លោក **ព្រឹន យ៉ាន** អ្នកស្រី **ហុង គិមអៀម**

វត្តធម្មរាមសព្វថ្ងៃនេះមានលោកតា លោកយាយស្នាក់នៅវត្តដើម្បីចាត់ចែងធ្វើចង្ហាន់ព្រឹក ថ្ងៃត្រង់ប្រគេនព្រះសង្ឃនិងរៀបចំ ទុកដាក់នូវទេយ្យទានផ្សេងៗ ដែលពុទ្ធបរិស័ទជិតឆ្ងាយបានប្រគេនចំពោះសង្ឃ ឯលោកតាលោកយាយទាំងអស់នោះដូច

មានរាយនាមតទៅនេះ ៖

| | | |
|---|---|---|
| លោកតា **ទូច ផន** | លោកតា **សុន ញ៉ឹក** | លោកតា **ញៀប ញឹម** |
| យុវជន **ជា ជេត** | យុវជន **ដារា វឿន** | លោក **សេង ប៊ុនថេត** |
| លោក **ឆាយ ថន** | លោក **ស៊ិន សែម** | លោកយាយ **អែម ឈា** |
| លោកយាយ **គង់ ម៉ុន** | លោកយាយ **ផាច ប៉ុន** | លោកយាយ **ទូច ចូ** |
| លោកយាយ **ផង់ ដាំ** | លោកយាយ **ផង់ ហុង** | លោកយាយ **ខែម សុន** |
| លោកយាយ **ចាប ម៉ា** | លោកយាយ **សោម ឥន្ទ** | លោកយាយ **គៀង ម៉ារិណា** |

លោកយាយ **សន ស៊ាន** លោកយាយ **អែម យ៉ុម** លោកយាយ **នង់ យន់** លោក **សរ មិន**

**វត្តធម្មារាម** ចេះតែរីកចំរើនធំឡើងៗ ពុទ្ធបរិស័ទជិតឆ្ងាយអញ្ជើញមកបំពេញបុណ្យទានយ៉ាងច្រើនកុះករ បណ្តាលឱ្យមានបញ្ហាចំណតឡានចោទឡើងយ៉ាងខ្លាំង ។ ព្រះសង្ឃនិងគណៈកម្មការវត្ត បានជាវដីនៅពីខាងកើតដីចាស់ ចំនួន ៥ អេគ័របន្ថែម ទៀត មានតម្លៃ $៤០០,០០០ បានបង់ឱ្យម្ចាស់ដីមុន $២០០,០០០ ដីនេះទិញនៅថ្ងៃទី ២៣ ខែឧសភាឆ្នាំ ២០០៩ ។

វត្តធម្មារាម

ក្រោមការគ្រប់គ្រងនិងដឹកនាំដ៏ឈ្លាសវៃនៃព្រះតេជព្រះគុណ **ធម្មលិខិត្តោ គុច ពុំ** និងព្រះអង្គគ្រូ **ឥន្ទប្បញ្ញោ គង់ ទិត្យ** ព្រមទាំងគណៈកម្មការនិងពុទ្ធបរិស័ទចំណុះជើងវត្តបានរួបរួមសាមគ្គីគ្នាយ៉ាងខ្លាំងក្លា ពួតដៃគ្នាធ្វើ **វត្តធម្មារាម** ឱ្យមានឈ្មោះល្បីល្បាញទាក់ទាញភ្ញៀវទេសចរ នៅរដ្ឋ និង នៅទីក្រុងនានាមកទស្សនា **វត្តធម្មារាម** ជាប់មិនដាច់ ។ ពេលបានទស្សនានូវទិដ្ឋភាពនៃរូបចម្លាក់ គេបានពោលសរសើរនូវស្នាព្រះហស្តនៃព្រះគុណព្រះអង្គគ្រូ **គង់ ទិត្យ** មិនដាច់ពីមាត់ ព្រមទាំងបានសរសើរនូវការរៀបចំទីកន្លែងកសាងស្ថាបនាបានមានរបៀបសមរម្យយ៉ាងក្រៃលែង ។

ព្រះសង្ឃ និង គណៈកម្មការសម្រាប់បំរើនូវកិច្ចការវត្តគ្រប់ផ្នែកទាំងអស់ មានបំណងនឹងពង្រីកនូវទីវត្តឱ្យមានវិសាលភាពកាន់តែប្រសើរឡើង តម្រូវតាមសេចក្តីត្រូវការនៃប្រជាពុទ្ធបរិស័ទនោះ នៅថ្ងៃព្រហស្បតិ៍ ៥ រោចខែមិគសិរឆ្នាំថោះ ត្រីស័ក **ព.ស.២៥៥៥** ត្រូវនឹងថ្ងៃទី ១៥ ខែធ្នូ **គ.ស. ២០១១** និងថ្ងៃសៅរ៍ ៧រោចខែមិគសិរ ឆ្នាំនិង ព.ស.ដដែល ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ **គ.ស. ២០១១** បានជាវដីនៅពីខាងកើតដីចាស់មានចំនួន ១៥ អេគ័រ មានផ្ទះ ១ ខ្នង ៣ បន្ទប់នៅលើដីនោះ តម្លៃទាំងអស់ ចំនួន $៤៨០,០០០ ។ ក្នុងការទិញដីនេះបាននាង **គុច គន្ធី** មានការស្និតស្នាញ

ខាងតវ៉ាដេញថ្លៃ ធ្វើឱ្យម្ចាស់អ្នកលក់មានចិត្ត ទោរទន់ ព្រមលក់តាមការសុំនិងការប៉ិនប្រសព្វញាត្តិរបស់នាង **គុច គន្ធី** ដោយគេចកែនឹងតម្លើងថ្លៃមិនបានឡើយ ។

ដូច្នេះ សរុបដីវត្តទាំងមុនទាំងក្រោយមានចំនួន ៣០ អេគ័រ ។

សូមញាតិញោមពុទ្ធបរិស័ទជិតឆ្ងាយទាំងអស់មេត្តាជួយជាវដីដែលទើបនឹងទិញថ្មីនេះសម្រាប់បូជាចំពោះគុណព្រះរតនៈត្រ័យដោយមានតម្លៃក្នុង ១ ម៉ែត្រក្រឡា $៣០ តាមសទ្ធា ។

ប្រវត្តិនៃ **វត្តធម្មារាម** ចម្លងតាមការសរសេររបស់លោកប្រធានគណៈកម្មការ **ផូ សាលួន** ខាងដើមចាប់ពីឆ្នាំ ១៩៩៣ គឺការចងចាំនិងការកត់ចំណាំរបស់ខ្ញុំព្រះករុណា ខ្ញុំបាទ **វ៉ាន់ អ៊ុង** ប្រសិនបើការសរសេររៀបរាប់នេះមានខ្វះចន្លោះត្រង់ណានោះ សូមទានមេត្តាខន្តីអភ័យទោស ។

ធ្វើនៅ**វត្តធម្មារាម**ថ្ងៃអង្គារ១០រោចខែបុស្សឆ្នាំថោះត្រីស័ក ព.ស.២៥៥៥ ត្រូវនឹងថ្ងៃទី ១៧ ខែមករា គ.ស.២០១២

បានឃើញនិងឯកភាព

| ព្រះចៅអធិការ | ព្រះឧបជ្ឈាយ៍ | អាចារ្យវត្ត | ប្រធានគណៈកម្មការ |
|---|---|---|---|
| **ធម្មលិខិត្ថេរោ** | **ភទ្ទប្បញ្ញោ** | **វ៉ាន់ អ៊ុង** | **ផូ សាលួន** |
| **គុច ពុំ** | **គង់ ទិត្យ** | | |

វត្តធម្មារាម

**វាយចម្លងប្រវត្តិសង្ខេប នៃ វត្តធម្មារាម ទីក្រុងស្តុកតុន ដោយខ្ញុំព្រះករុណាខ្ញុំបាទ អ៊ិន លី ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២**

**សេចក្តីបន្ថែម:** ក្នុងឆ្នាំ២០១២ការសាងសង់រោងសិល្បៈសាជាថ្មី អស់ទឹកប្រាក់ចំនួន $៥០,០០០.០០ សារុប្បទាំងការរចនារូបចម្លាក់ អប្សរា និង រូបប្រាសាទអង្គរវត្ត ជាស្នាព្រះហស្តព្រះតេជព្រះគុណ **គង់ ទិត្យ**។

ឆ្នាំ២០១៣ វត្តបានដាក់របងដីទើបតែជាវថ្មី នៅទិសបូព៌ដីចាស់ អស់ទឹកប្រាក់ $១០០,០០០.០០ នេះសារុប្បទាំងផ្លូវស៊ីម៉ងត៍ចាក់ថ្មីពីដីចាស់ទៅដល់របងធ្វើថ្មី ក្រោមការដឹកនាំដ៏ឈ្លាសវៃនៃព្រះតេជព្រះគុណ **ធម្មលិខិត្ថេរោ គុច ពុំ** ព្រមទាំងព្រះតេជព្រះគុណ **ភទ្ទប្បញ្ញោ គង់ ទិត្យ** ។

គ.ស.២០១៤ សំណង់រោងដែកសម្រាប់ប្រារព្ធពិធីបុណ្យធំៗបានរួចជាស្ថាពរ ព្រមទាំងបានប្រារព្ធពិធីបុណ្យសម្ពោធន៍បើកឲ្យប្រើជាផ្លូវការ ក្នុងថ្ងៃទី១៤កើត ខែភទ្របទ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨ អស់ទឹកប្រាក់ចំនួន $៣,៣៣០៧.០០ ក្រោមការដឹកនាំដ៏ឈ្លាសវៃនៃព្រះតេជព្រះគុណ **ធម្មលិខិត្ថេរោ គុច ពុំ** ព្រមទាំងព្រះតេជព្រះគុណ **ភទ្ទប្បញ្ញោ គង់ ទិត្យ** ។